01030368

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 14 / 10 / 2014
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

E316/1/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤

**ជូនចំពោះ:** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំធ្វើសេចក្តីថ្លែងបើក

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើមួយ ពីសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំអនុញ្ញាតធ្វើសេចក្តីថ្លែងបើកនៅថ្ងៃដំបូងនៃសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២ (ឯកសារ E316/1)។ ដូចបានកត់សម្គាល់ដោយសហមេធាវីនាំមុខ អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានបដិសេធសំណើរបស់សហមេធាវីនាំមុខ សុំធ្វើសេចក្តីថ្លែងបើកនៅក្នុងសំណុំរឿង ០០២/០១ ចំនួនពីរដងរួចមកហើយ ដោយសារតែពុំមានបទប្បញ្ញត្តិណាមួយដែលអនុញ្ញាតឲ្យសហមេធាវីនាំមុខធ្វើសេចក្តីថ្លែងបើកនេះ នៅក្នុងក្របខណ្ឌគតិយុត្តនៃ អ.វ.ត.ក ឡើយ (ឯកសារ E131/4/1 ឯកសារ E1/14.1 ទំព័រ ៦៨-៧០)។ ដូចគ្នាដែរ អង្គជំនុំជម្រះសាលាដំបូងក៏ធ្លាប់បានបដិសេធសំណើមួយ របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំធ្វើសេចក្តីថ្លែងបើកនៅក្នុងសំណុំរឿង ០០១ (ឯកសារ E23/4 សំណុំរឿង ០០១) ផងដែរ។

២. សហមេធាវីនាំមុខលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងគួរពិចារណាជំហាររបស់ខ្លួនសាឡើងវិញដោយសារតែមានកាលៈទេសៈថ្មីៗដូចជា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីលក្ខណៈនៃបណ្តុំដើមបណ្តឹងរដ្ឋប្បវេណីដែលរួមគ្នាជាក្រុមតែមួយ ដីកាកំណត់កាល

បរិច្ឆេទបើកសវនាការនៅក្នុងសំណុំរឿង ០០២/០២ និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលដែលបានចេញក្នុងពេលថ្មីៗនេះ ដែលបានបញ្ជាក់ថា សំណុំរឿង ០០២/០២ គឺជាការជំនុំជម្រះដាច់ដោយឡែកមួយ (E316/1 កថាខណ្ឌ ១០-១១)។ សហមេធាវីនាំមុខមិនបានពន្យល់ ថាតើសេចក្តីសម្រេចទាំងនេះបានបង្កើតឲ្យមានការផ្លាស់ប្តូរកាលៈទេសៈទាក់ទងនឹងការធ្វើសេចក្តីថ្លែងបើកដែរ ឬយ៉ាងណានោះទេ។ វិធាន ៨៩*ស្ទួន* នៃវិធានផ្ទៃក្នុង ដែលមិនមានការកែប្រែនោះ ចែងថា មានតែសហព្រះរាជអាជ្ញា ជនជាប់ចោទ និងមេធាវីរបស់ខ្លួនតែប៉ុណ្ណោះដែលមានសិទ្ធិធ្វើសេចក្តីសន្និដ្ឋានអំពីការចោទប្រកាន់។ ហេតុដូច្នេះ អង្គជំនុំជម្រះច្រាលចោលសំណើសុំឲ្យពិចារណាឡើងវិញនេះ។

៣. សេចក្តីសម្រេចនេះគឺជាការឆ្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះចំពោះឯកសារ E316/1។